Living the LOTUS
Buddhism in Everyday Life
New Year's Issue 2019

New Year's Message

# ចូរយើងវិវត្តខ្លួនយើងទៅមុខ

ព្រះសង្ឃនីវ៉ាណូ និជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## ＜ការបណ្តុះបណ្តាលមនុស្ស＞គឺជាប្រធានបទដ៏សំខាន់បំផុតសម្រាប់ការកសាងសង្គមនិងប្រទេសជាតិនាអនាគតកាល

សូមជូនពរឆ្នាំថ្មី។
ឆ្នាំមុនគឺជាឆ្នាំខួបគម្រប់៨០ឆ្នាំនៃអង្គការរីស្សូកូសេកៃ។គឺជាឆ្នាំសំខាន់សម្រាប់ឱ្យយើងកំណត់នូវការងារបន្តទៅមុខទៀត។ពីឆ្នាំនេះទៅមុខសូមឱ្យយើងរួបរួមកម្លាំងចិត្តគ្នាខិតខំព្យាយាមបោះពួយសំដៅទៅរកខួប១០០ឆ្នាំខាងមុខ។

ក្នុងន័យនេះខ្ញុំព្រះករុណាអាត្មាភាពសូមជម្រាបពី＜ទិសដៅសម្រាប់ឆ្នាំ២០១៩＞ដូចតទៅនេះ៖
ភពផែនដីព្រមទាំងធម្មជាតិតែងតែបង្កបង្កើតហើយប្រែប្រួលដដែលៗមិនដែលឈប់សំរាកមួយប៉ប្រិចសោះឡើយ។យើងទាំង ឡាយជាមនុស្សលោកក៏ដូច្នេះដែរយើងតោងតែប្រកបការងារនិងជីវភាពរស់នៅប្រចាំថ្ងៃដោយអារម្មណ៍ស្រស់ថ្មីមិនឈប់ទ្រឹងទៅតាមហេតុផលត្រឹមត្រូវនៃពិភពផែនដីដែរ។

ឆ្នាំនេះយើងឈានជើងចូលទៅឆ្នាំគម្រប់ខួបទី៨១ហើយ។នេះគឺជាសមិទ្ធិផលដែលកៃស្សូសាម៉ា និង វ៉ាគីកៃស្សូសាម៉ាលោកបានខិតខំកសាងមិនស្គាល់យប់មិនស្គាល់ថ្ងៃជាមួយនឹងរៀមច្បងមន្ត្រីជាន់ខ្ពស់ទាំងឡាយនៃអង្គការរីស្សូកូសេកៃ។

យើងខ្ញុំទាំងអស់គ្នានឹងដាក់គោលដៅច្បាស់លាស់មួយ

# New Year's Message 2019

ដើម្បីតម្រង់ឆ្ពោះដោយភាពកសាងឆ្នៃប្រឌិតទៅរកខួបទី១០០នៃអង្គការយើងដើម្បីសងព្រះគុណលោកអ្នកទាំងអស់នោះ។

អត្ថន័យនៃអត្ថបទនេះភាគច្រើនមិនខុសគ្នាពីអត្ថបទដែលខ្ញុំព្រះករុណាអាត្មាភាពបានសរសេរនៅឆ្នាំមុនឡើយ តែជាករណីសំខាន់ ដែលសមាជិកនៃអង្គការយើងតោងតែលើកយកមកគិតជានិច្ចជាកាល។

នៅក្នុងទីសដៅប្រចាំឆ្នាំនេះខ្ញុំព្រះករុណាអាត្មាភាពបានប្រើពាក្យ＜ជំហានទៅមុខប្រ
កបដោយការបង្កើតតាមបែបឆ្នៃប្រឌិត＞។

ពាក្យនេះមិនគ្រាន់តែមានន័យថាបង្កើតនូវរបស់ថ្មីតែប៉ុណ្ណោះទេ។

ទស្សនៈព្រះពុទ្ធសាសនាជាទស្សនៈដែលហួសផុតពីរឿង ឈ្នះ ចាញ់ ជោគជ័យ បរាជ័យ ថ្មីឬចាស់គឺជាទស្សនៈសាកល ដែលចែងថាទោះជានៅក្នុងសម័យកាលណាក៏ដោយមនុស្សត្រូវមានចិត្តភ្លឺថ្លាស្រស់បំព្រង,ស្លូតបូត,ទន់ភ្លន់ហើយកក់ក្តៅដែលអាចផ្តល់ទៅឱ្យអ្នកដទៃនូវកម្លាំងពិតប្រាកដសម្រាប់ការរស់នៅ។មនុស្សម្នាក់ៗតោងតែក្លាហានហ៊ានបង្ហាញដោយគ្មានក្តីសោកស្តាយនូវទឹកចិត្តបែបនេះចំពោះមនុស្សនៅក្នុងគ្រួសារ,សាលរៀន,កន្លែងធ្វើការ,សហគមន៍និងសាកលលោក។ហ្នឹងហើយដែលគេហៅថា ជំហានប្រកបទៅដោយការបង្កើតតាមបែបឆ្នៃប្រឌិតពិតប្រាកដនោះ។



ចូរយើងម្នាក់ៗកុំភ្លេចនូវទង្វើជាមូលដ្ឋាននេះហើយប្រើបុគ្គលិកលក្ខណៈពិសេសរបស់ខ្លួនម្នាក់ឱ្យបានការឱ្យមានការបន្តផ្ជាប់ទៅនឹងកិច្ចប្រត្តិបត្តិស្រួលៗ។

អាត្មាភាពបាននិយាយនាឱកាសបុណ្យខួបអង្គការយើងគម្រប់៨០ឆ្នាំដើម្បីនឹងអាចបោះជំហានឆ្ពោះទៅរកខួបគម្រប់១០០ឆ្នាំដែលនឹងត្រូវតែចូលមកថា៖យើងទាំងអស់គ្នាត្រូវខំប្រឹងប្រែងអោយអស់ពីសមត្ថភាពទៅលើការបណ្តុះបណ្តាលធនធានមនុស្ស, បណ្តុះមនុស្សដែលជាប្រធានបទជាមូលដ្ឋាន។

＜បណ្តុះមនុស្ស＞ ជាពាក្យដែលមានប្រើនៅក្នុងសៀវភៅចិនសម័យបុរាណ។

ពីមុនអាត្មាភាពធ្លាប់បានសរសេរនៅក្នុងសេចក្តីបន្ថែមនៃទីសដៅប្រចាំឆ្នាំថា៖បើធ្វើគម្រោងសម្រាប់មួយឆ្នាំត្រូវដាំធញ្ញជាតិ។បើធ្វើគម្រោងសម្រាប់១០ឆ្នាំត្រូវដាំដើមឈើ, បើធ្វើគម្រោងសម្រាប់មួយជីវិត គ្មានអ្វីប្រសើរជាងការបណ្តុះមនុស្សទេ។នៅសម័យបុរាណចិនគេសរសេរពាក្យ＜ដាំឬបណ្តុះ（植える）＞ដោយយកអក្សរ＜ឈើ（樹える）＞មកសរសេរដែលសឱ្យឃើញថា
បណ្តុះមិនមានន័យត្រឹមតែដាំប៉ុណ្ណោះទេ តែមានន័យដល់ទៅថាដាំដើមឈើទៅទៀតដូច្នេះទើបបានជាមានពាក្យទំនៀមមួយឃ្លាចែងថា＜ប្រៀបដូចនឹងបានដាំដើមឈើបីដើម（三樹の譬え）＞។

ការបណ្តុះបណ្តាលធនធានមនុស្សគឺជា＜គម្រោងប្រចាំមួយជីវិត＞ គឺជាប្រធានបទដែលមនុស្សតោងតែយកមកគិតគូរ、អនុវត្តពេញមួយជីវិតរបស់ខ្លួន។ពោលគឺថាជាប្រធានបទដ៏សំខាន់បំផុតសម្រាប់ការកសាងសង្គមឬប្រទេសជាតិតទៅអនាគតកាលដ៏យូរអង្វែង។

ម្យ៉ាងទៀតការបណ្តុះបណ្តាលធនធានមនុស្សអាចប្រៀបប្រដូចទៅនឹងការដាំដើមឈើមួយដើមៗដូច្នេះដែរ។ប្រសិនបើដើមឈើនោះចាក់ឫសជ្រៅទៅក្នុងដីហើយទោះជាអ្នកដាំមិននៅក្តីក៏ដើមឈើអាចនឹងលូតលាស់ធំធាត់ទៅបានដែរ។ពាក្យថា
បណ្តុះបណ្តាលមនុស្សគឺជាពាក្យដែលបង្ហាញនូវសារៈសំខាន់នៃការបណ្តុះបណ្តាលមនុស្សឱ្យអាចឈរជើងពីររស់នៅបានដោយខ្លួនឯងប្រកបទៅដោយមោទនភាពនោះឯង។

## គ្រួសារគឺជាទីកន្លែងមូលដ្ឋានសម្រាប់ចងក្រងកសាងអត្តចរិតរបស់មនុស្ស។ទង្វើរបស់មាតាបិតាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើបុត្រធីតា

នៅក្នុងការពិតជាក់ស្តែង ចំណុចសំខាន់ពិសេសសម្រាប់ការបណ្តុះបណ្តាលមនុស្ស គឺទំនាក់ទំនងរវាងមនុស្សនិងមនុស្សចាប់ពីកុមារវ័យ និយាយឱ្យខ្លីគឺការបណ្តុះបណ្តាលនៅក្នុងគ្រួសារតែម្តង។

រហូតដល់អាយុប្រហែល៣ឆ្នាំ,ខួរក្បាលរបស់មនុស្សលូតលាស់បាន៨០ភាគរយនៃមុខងាររបស់មនុស្សពេញវ័យ។ ដល់អាយុ៥ឬ៦ឆ្នាំអត្តចារឹតរបស់មនុស្សត្រូវបានកំណត់ស្រេចបាច់។ខួរក្បាលល្អឬមិនល្អ, សេចក្តីប្រុងប្រយ័ត្នក្នុងការស្តាប់ឬធ្វើការងារឡើងខ្ពស់ដល់កំណត់នៅអាយុ១២ឬ១៣ឆ្នាំ។ នៅអាយុ១៦ឬ១៧លក្ខណៈជាមនុស្សបានឡើងពេញលេញទាំងកាយនិងចិត្តសម្បទា។

គ្រួសារគឺជាទីកន្លែងចងក្រងកសាងនៃអត្តចារឹតរបស់មនុស្ស។ដូច្នេះបើនិយាយពីសមាជិកនៃអង្គការយើង,នៅពេលដែលឃើញមាតាបិតាសូត្រឬអានធម៌ឬក៏ថ្វាយបង្គំព្រះ ថ្លែងអំណរគុណចំពោះព្រះពុទ្ធរូបព្រឹកល្ងាច កុមារក៏ទទួលឥទ្ធិពលពីនោះច្រើន។ម្យ៉ាងទៀតនៅពេលដែលឃើញមាតាបិតាញញឹមញញែមរីករាយ ស្លូតបូត ហើយកក់ក្តៅចំពោះខ្លួន,កុមារក៏នឹងក្លាយទៅជាមនុស្សប្រកបទៅដោយភាពរួសរាយកក់ក្តៅដែរ។

ផ្ទុយទៅវិញប្រសិនបើមាតាបិតាប្រើពាក្យអសុរសជានិច្ចជាកាល កុមារក៏នឹងត្រងត្រាប់តាមហើយទទួលយកបន្តនូវភាពគ្រោតគ្រាតនោះមកដាក់ខ្លួនយ៉ាងងាយបំផុតមិនបាច់ចាំដាក់ជី។ម្យ៉ាងទៀតបើមាតាបិតាបង្ខំកូនឱ្យធ្វើតាមចិត្តខ្លួនពេលនោះកូនអាចធ្វើតាមមែន ក៏ប៉ុន្តែធ្វើទាំងមិនចង់នាំឱ្យជួនកាលទៅជា

បញ្ច្រាសស្រកីមកវិញហើយរត់ចេញទៅឆ្ងាយបាត់លែងខ្វល់នឹងឪពុកម្តាយក៏មាន។

ឧបមាដូចជាគេដោតឈើកោងមួយនៅលើដីរួចចង់ពត់ស្រមោលឈើនោះឱ្យត្រង់ហើយវាមិនអាចធ្វើបានបែបនោះដែរ។ប្រសិនបើដោតឈើឱ្យត្រង់ទៅលើពេលនោះស្រមោល វាក៏ត្រង់ទៅតាមនោះដែរ។

សំដីសំដៅរបស់កូន គឺជាកញ្ចក់ឆ្លុះបញ្ចាំងនូវទង្វើជារៀងរាល់ថ្ងៃរបស់មាតាបិតា។បញ្ហារបស់កុមារឬយុវជនដែលកើតមានឡើងនៅក្នុងសង្គមក៏គឺជាកញ្ចក់ដែលឆ្លុះបញ្ចាំងនូវរូបរាងដែលខ្លួនមិនចង់ឃើញនៃពិភពរបស់មនុស្សធំដែលជាអាណាព្យាបាល។

អ្វីដែលសំខាន់គឺឪពុកម្តាយនិងមនុស្សធំត្រូវរៀបចំខ្លួនឱ្យបានល្អសិនសឹមសង្ឃឹមលើកូនៗឱ្យគេក្លាយជាមនុស្សដែលខ្លួនរំពឹងនិងប្រាថ្នា។

លោកសាស្ត្រាចារ្យយ៉ាស៊ឺអូកាដែលជាអ្នកឯកទេសល្បីល្បាញខាងទស្សនវិទ្យាបូព៌ាប្រទេសបានសរសេរថា៖ឪពុកគួរតែធ្វើខ្លួនឱ្យទៅជាមនុស្សជាទីគោរពនៃបុត្រធីតា ហើយម្តាយគួរតែជាមនុស្សដែលមានមេត្តាករុណាពីព្រោះថាគ្រួសារគឺជាថ្នាលសម្រាប់បណ្តុះកូនចៅ។

ប្រសិនបើថ្នាលសម្រាប់សាបសំណាបមិនត្រូវបានភ្ជួររាស់ត្រឹមត្រូវទេនោះគេក៏មិនអាចសង្ឃឹមថានឹងអាចច្រូតកាត់បានផលស្រូវនៅរដូវលំហើយបានឡើយ។



## សេចក្ដីប្រាថ្នាដ៏ធំបំផុតនៃព្រះសម្មាសម្ពុទ្ធ គឺចង់ឱ្យមនុស្សទាំងឡាយប្រព្រឹត្តជីវភាពដោយដើរតាមមាគ៌ានៃព្រះពោធិសត្វ

យោលទៅតាមសេចក្ដីដូចដែលបានជម្រាបមកពីខាងលើមកហើយៗដែលអាត្មាភាពតែងតែនិយាយហើយនិយាយទៀតថា សូមឱ្យអ្នកទាំងអស់ប្រកាន់ចិត្តមេត្តាករុណាដូចព្រះសម្មាសម្ពុទ្ធឬក៏កែសូសាម៉ានិងវ៉ាគីសូសាម៉ាឱ្យមានចិត្តល្អ,កក់ក្ដៅដែលជាចិត្តមនុស្សធម៌ហើយដើរតាមមាគ៌ានៃព្រះពោធិ សត្វឬមាគ៌ាមនុស្សធម៌។

ការដើរតាមមាគ៌ាព្រះពោធិសត្វនេះបើយោលតាមព្រះធម៌បទុមសូត្រគឺជាសេចក្ដីប្រាថ្នានៃព្រះសម្មាសម្ពុទ្ធទៅលើរបៀបរស់នៅរបស់មនុស្សលោក។

ដែលហៅថាព្រះពោធិសត្វ គឺអ្នកដែលជឿលើព្រះធម៌, យល់ច្បាស់ពីព្រះធម៌ហើយសម្រេចចិត្តថាព្យាយាមដើរតម្រង់ឆ្ពោះទៅជាព្រះពុទ្ធ។និយាយឱ្យស្រួលយល់គឺអ្នកដែលខិតខំកសាងចិត្តខ្លួនឱ្យមានចិត្តព្រះ។

ហើយក្បាលម៉ាស៊ីនដែលផ្ដល់កម្លាំងចិត្តសម្រាប់ការរស់នៅរបស់ព្រះពោធិសត្វគឺមេត្តាករុណា។

ដើម្បីឱ្យបានក្លាយជាព្រះពោធិសត្វគេមិនមែនសិក្សាទៅតាមចំណង់ចិត្តរបស់ខ្លួននោះឡើយ គឺត្រូវសិក្សាតាមវិធីដែលព្រះពុទ្ធអង្គលោកបានកំណត់មកគឺសិក្សាព្រះធម៌។

និយាយពីការសិក្សា បើមើលពីអក្សរចិន

គេសរសេរថា「習学」ដែលបកប្រែថាការសិក្សានោះ វាមានអក្សរ「習」ដែលចែកចេញជាអក្សរ「羽」 (ស្លាប) ដែលនៅខាងលើនិង「白」 (ពណ៌ស) នៅពីក្រោមនោះ។ អក្សរស្លាបនេះបង្ហាញពីស្លាបដែលចាប់ដុះពីខ្លួនកូនបក្សីបង្ហាញថាវាអាចហើរបែកពីសំបុកនិង ពីការធ្វើត្រាប់តាមមេបាដោយត្រដាងស្លាបហើយទទះ ហាត់រៀនហោះហើរ។

ចូរយើងប្រត្តិបត្តតាមកូនបក្សីដែលប្រុងនឹងបែកលំនៅពីមេបាដោយខំសិក្សាស្វាធ្យាយធម៌ព្រះពុទ្ធដោយត្រឹមត្រូវហើយយកមកអនុវត្តបណ្ដើរគិតបណ្ដើរនៅក្នុងជីវភាពរស់នៅរាល់ថ្ងៃ ដដែលៗ។យោលទៅតាមទង្វើនេះ យើងកាន់តែឈានជើងចូលទៅជិតចិត្តគំនិតរបស់ព្រះសម្មាសម្ពុទ្ធបានហើយ។

អ្នកដែលជួយជ្រោមជ្រែងអ្នកក្នុងការសិក្សារាល់ថ្ងៃដូចមេបក្សីដែលចាំថៃទាំកូនទម្រាំវាដុះស្លាបហើរបាននោះគឺគ្មាននរណាក្រៅពីព្រះសង្ឃឡើយ។នៅពេលដែលនៅជុំវិញខ្លួនមានអ្នកដែលកាន់ពុទ្ធសាសនាដូចគ្នាជួយលើកទឹកចិត្តនិងបង្រៀន,ឧបាសកឧបាសិកាទាំងឡាយក៏មានការកក់ក្ដៅក្នុងចិត្តហើយអាចស្វាធ្យាយសិក្សាធម៌បាន។

ក៏ប៉ុន្តែចំពោះអ្នកដែលទើបនឹងចូលមករៀនព្រះធម៌ថ្មីថ្មោង មានអ្នកខ្លះគិតថា<ខ្លួនមិនមែនជាមនុស្សត្រឹមត្រូវគ្រប់ដប់ មិនអាចទៅជាតួអង្គព្រះពោធិសត្វបានឡើយ> ហើយក៏ទៅជាស្ទាក់ស្ទើរ។

ជាការពិតណាស់ ធាតុជាមនុស្សតែងមានការលោភលន់កំហឹង ភាពល្ងិតល្ងង់ជាដើមដែលជាតណ្ហា។ ហើយជាធម្មតាយើងច្រើនគិតថាតណ្ហាគឺជាធាតុអាក្រក់ មិនត្រូវមានតណ្ហាឡើយ។ក៏ប៉ុន្តែតាមពិតទៅ,ដោយសារតែមានតណ្ហានេះហើយទើបនាំឱ្យមនុស្សមានសេចក្ដីបារម្ភ,មានទុក្ខហើយដោយសារ តែមានទុក្ខទើបមនុស្សចង់ដោះស្រាយចង់ចាកចេញឱ្យផុតពីទុក្ខនោះរួចក៏រត់រកពុទ្ធិ （ពោលគឺការត្រាស់ដឹង） នោះឯង។

និយាយឱ្យស្រួលយល់ទៅគឺយើងចាប់ភ្លឹកថា តណ្ហាគឺជាការត្រាស់ដឹង ហើយការចាប់ភ្លឹកនេះជាចំណុចសំខាន់។

ព្រមជាមួយនឹងគ្នានេះដែរ យើងចាប់ផ្ដើមយល់ដឹងថាមនុស្សគ្រប់គ្នាសុទ្ធតែមានមេត្តាធម៌នៅក្នុងចិត្តដូចព្រះពុទ្ធដែរ។

នៅពេលជួយយកអាសារឬផ្ដល់យោបល់ដល់អ្នកដែលមានទុក្ខព្រួយ,ហើយពេលឃើញអ្នកនោះបានចាកផុតពីទុក្ខព្រួយ ពេលខ្លះយើងក៏មានសេចក្ដីសប្បាយរីករាយអស្ចារ្យសឹងតែថាលើសពីរឿងផ្ទាល់របស់ខ្លួនក៏មានដែរ។ពេលយើងដើររើសសម្រាមដែលគេចោលតាមផ្លូវ ពេលជូនវិភាគទានឬដាក់ទាន, ពេលជូនកៅអីដែលខ្លួនកំពុងអង្គុយនៅក្នុងរថទៅអ្នកដែលពិការឬចាស់ជរា ឬនារីមានផ្ទៃពោះជាដើមក៏ធ្វើឱ្យចិត្តយើងសប្បាយរីករាយជ្រះថ្លាដែរ។នេះជាកស្សិនថាមនុស្សមានចិត្តមេត្តាដូចជាព្រះសម្មា សម្ពុទ្ធដែរ។

យើងម្នាក់ៗត្រូវជឿទៅលើសមត្ថភាពដែលខ្លួនមាន,ត្រូវតាំងចិត្តថានឹងរស់តាមមាគ៌ាព្រះពោធិសត្វហើយនឹងបណ្ដុះបណ្ដាលព្រះពោធិសត្វជាបន្តបន្ទាប់ទៅមុខទៀតទៅតាមសមត្ថភាពរបស់ខ្លួន។

អាត្មាភាពសូមបង្វែរទៅប្រធានបទផ្សេង

បន្តិច។នៅខែឧសភាខាងមុខនេះ ព្រះចៅអធិរាជជប៉ុនលោកនឹងដាក់រាជ្យហើយសម័យ<ហោយសេយ>ក៏នឹងត្រូវបានបញ្ចប់ដែរ។ពាក្យថា<ហោយសេយ>នេះដកស្រង់ពីពាក្យចិនបុរាណដែលមានន័យថា <បើនៅក្នុងចិត្តមនុស្សនិងនៅក្នុងប្រទេសមានសេចក្តីសុខស្ងប់ស្ងាត់,សភាពនោះនឹងបញ្ចេញឱ្យឃើញមកក្រៅ>។ពួកយើងដែលបានរស់នៅសម័យហោយសេយគួរតែរស់តាមទស្សនៈនិងឧត្តមគតិដែលន័យនៃសម័យនេះបង្កប់ទើបត្រូវ។

បញ្ហានានាដែលមាននៅក្នុងពិភពពិតមិនអាចដោះស្រាយបានដោយការអង្គុយរង់ចាំអ្នកដទៃមកដោះស្រាយជំនួសឱ្យឡើយ។ឧទាហរណ៍ដូចជាព្រះពុទ្ធអង្គលោកបានឱ្យព្រះពោធិសត្វមួយអង្គព្រះនាមជីវ៉ាគីទៅផ្សព្វផ្សាយព្រះធម៌បទុមសូត្រទ្រង់បានទូន្មានថាបញ្ហាទាំងឡាយតែងតែបានត្រូវដោះស្រាយដោយទង្វើនៃមនុស្សសាមញ្ញទូទៅដែលគ្មានឈ្មោះបោះសម្លេងហើយដែលខំរស់ទាំងត្រដរទាំងទុក្ខសោកលំបាកលំបិននៅក្នុងពិភពពិតៗតែប៉ុណ្ណោះ។

ដូច្នេះមនុស្សម្នាក់ៗមិនត្រូវមើលងាយសមត្ថភាពខ្លួនឯង,ត្រូវជឿហើយយល់ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធរួចហើយដើរតាមមាគ៌ានៃព្រះពោធិសត្វដោយចិត្តមេត្តាករុណា។នេះគឺជាគោលដៅនៃសេចក្តីព្យាយាមរបស់យើងនិងជាប្រធានបទចំបងនៃព្រះធម៌បទុមសូត្រ។

អាត្មាភាពចារសេចក្តីនេះទុកក្នុងជម្រៅនៃបេះដូងហើយឆ្នាំនេះក៏ដូចឆ្នាំមុនៗដែរក្នុងសេចក្តីសង្ឃឹមថានឹងបានកាន់ដៃអ្នកទាំងអស់ធ្វើដំណើរបន្តទៅមុខជាមួយគ្នាទៀត។

(កាសែតកូសេលេខថ្ងៃទី៦ខែមករាឆ្នាំ២០១៩)



# Rissho Kosei-kai: A Global Buddhist Movememt




**Rissho Kosei-kai International**
Fumon Media Center 3F, 2-7-1 Wada, Suginami-ku, Tokyo, Japan
*Tel:* 81-3-5341-1124 *Fax:* 81-3-5341-1224
*e-mail:* living.the.lotus.rk-international@kosei-kai.or.jp

**Rissho Kosei-kai International of North America (RKINA)**
2707 East First Street, Suite #1, Los Angeles, CA 90033, U.S.A
*Tel:* 1-323-262-4430 *Fax:* 1-323-262-4437
*e-mail:* info@rkina.org http://www.rkina.org

**Branch under RKINA**

**Rissho Kosei-kai of Seattle's Buddhist Learning Center**
28621 Pacific Highway South, Federal Way, WA 98003 U.S.A.
*Tel:* 1-253-945-0024 *Fax:* 1-253-945-0261
*e-mail:* rkseattlewashington@gmail.com
http://buddhistlearningcenter.org/

**Rissho Kosei-kai Buddhist Center of San Antonio**
6083 Babcock Road, San Antonio, TX 78240, U.S.A.
P.O. Box 692148, San Antonio, TX78269, U.S.A
*Tel:* 1-210-561-7991 *Fax:* 1-210-696-7745
*e-mail:* dharmasanantonio@gmail.com
http://www.rkina.org/sanantonio.html

**Rissho Kosei-kai of Tampa Bay**
2470 Nursery Road, Clearwater, FL 33764, U.S.A.
*Tel:* (727) 560-2927 *e-mail:* rktampabay@yahoo.com
http://www.buddhismtampabay.org/

**Rissho Kosei-kai of Vancouver**

**Rissho Kosei-kai Buddhist Church of Hawaii**
2280 Auhuhu Street, Pearl City, HI 96782, U.S.A.
*Tel:* 1-808-455-3212 *Fax:* 1-808-455-4633
*e-mail:* info@rkhawaii.org http://www.rkhawaii.org

**Rissho Kosei-kai Maui Dharma Center**
1817 Nani Street, Wailuku, HI 96793, U.S.A.
*Tel:* 1-808-242-6175 *Fax:* 1-808-244-4625

**Rissho Kosei-kai Kona Dharma Center**
73-4592 Mamalahoa Highway, Kailua-Kona, HI 96740 U.S.A.
*Tel:* 1-808-325-0015 *Fax:* 1-808-333-5537

**Rissho Kosei-kai Buddhist Center of Los Angeles**
2707 East First Street, Los Angeles, CA 90033, U.S.A.
*Tel:* 1-323-269-4741 *Fax:* 1-323-269-4567
*e-mail:* rk-la@sbcglobal.net http://www.rkina.org/losangeles.html

**Rissho Kosei-kai Buddhist Center of Arizona**
**Rissho Kosei-kai Buddhist Center of Colorado**
**Rissho Kosei-kai Buddhist Center of San Diego**
**Rissho Kosei-kai Buddhist Center of Las Vegas**
**Rissho Kosei-kai Buddhist Center of Dallas**

**Rissho Kosei-kai of San Francisco**
1031 Valencia Way, Pacifica, CA 94044, U.S.A.
*Tel:* 1-650-359-6951 *Fax:* 1-650-359-6437
*e-mail:* info@rksf.org http://www.rksf.org

**Rissho Kosei-kai of Sacramento**
**Rissho Kosei-kai of San Jose**

**Rissho Kosei-kai of New York**
320 East 39th Street, New York, NY 10016 U.S.A.
*Tel:* 1-212-867-5677 *Fax:* 1-212-697-6499
*e-mail:* rkny39@gmail.com http://rk-ny.org/

**Rissho Kosei-kai of Chicago**
1 West Euclid Ave., Mt. Prospect, IL 60056 U.S.A.
*Tel :* 1-773-842-5654 *e-mail:* murakami4838@aol.com
http://rkchi.org/

**Rissho Kosei-kai of Fort Myers**
http://www.rkftmyersbuddhism.org/

**Rissho Kosei-kai Dharma Center of Oklahoma**
2745 N.W. 40th Street, Oklahoma City, OK 73112 U.S.A.
*Tel:* 1-405-943-5030 *Fax:* 1-405-943-5303
*e-mail:* rkokdc@gmail.com http://www.rkok-dharmacenter.org

**Rissho Kosei-kai Dharma Center of Denver**
1255 Galapago Street, #809 Denver, CO 80204 U.S.A.
*Tel:* 1-303-446-0792

**Rissho Kosei-kai Dharma Center of Dayton**
425 Patterson Road, Dayton, OH 45419 U.S.A.
http://www.rkina-dayton.com/

**Risho Kossei-kai do Brasil**
Rua Dr. José Estefno 40, Vila Mariana, São Paulo-SP,
CEP 04116-060 Brasil
*Tel:* 55-11-5549-4446 / 55-11-5573-8377 *Fax:* 55-11-5549-4304
*e-mail:* risho@terra.com.br http://www.rkk.org.br

**Risho Kossei-kai de Mogi das Cruzes**
Av. Ipiranga 1575-Ap 1, Mogi das Cruzes-SP,
CEP 08730-000 Brasil
*Tel:* 55-11-5549-4446 / 55-11-5573-8377

**Rissho Kosei-kai of Taipei**
4F, No. 10 Hengyang Road, Jhongjheng District,
Taipei City 100, Taiwan
*Tel:* 886-2-2381-1632 *Fax:* 886-2-2331-3433
http://kosei-kai.blogspot.com/

**Rissho Kosei-kai of Tainan**
No. 45, Chongming 23rd Street, East District,
Tainan City 701, Taiwan
*Tel:* 886-6-289-1478 *Fax:* 886-6-289-1488

**Korean Rissho Kosei-kai**
6-3, 8 gil Hannamdaero Yongsan gu, Seoul, 04420,
Republic of Korea
*Tel:* 82-2-796-5571 *Fax:* 82-2-796-1696
*e-mail:* krkk1125@hotmail.com

**Korean Rissho Kosei-kai of Busan**
3F, 174 Suyoung ro, Nam gu, Busan, 48460, Republic of Korea
*Tel:* 82-51-643-5571 *Fax:* 82-51-643-5572

**International Buddhist Congregation (IBC)**
Fumon Media Center 3F, 2-7-1 Wada, Suginami-ku, Tokyo, Japan
*Tel:* 81-3-5341-1230 *Fax:* 81-3-5341-1224
*e-mail:* ibcrk@kosei-kai.or.jp http://www.ibc-rk.org/

**Branches under the Headquarters**

**Rissho Kosei-kai of Hong Kong**
Flat D, 5/F, Kiu Hing Mansion, 14 King's Road,
North Point, Hong Kong, Republic of China

**Rissho Kosei-kai of Ulaanbaatar**
15F Express tower, Peace avenue, khoroo-1, Chingeltei district,
Ulaanbaatar 15160, Mongolia
*Tel:* 976-70006960 *e-mail:* rkkmongolia@yahoo.co.jp

**Rissho Kosei-kai of Sakhalin**
4 Gruzinski Alley, Yuzhno-Sakhalinsk
693005, Russian Federation
*Tel & Fax:* 7-4242-77-05-14

**Rissho Kosei-kai Friends in Shanghai**

**Rissho Kosei-kai of South Asia Division**
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang
Bangkok 10310, Thailand
*Tel:* 66-2-716-8141 *Fax:* 66-2-716-8218

**Rissho Kosei-kai International of South Asia (RKISA)**
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang
Bangkok 10310, Thailand
*Tel:* 66-2-716-8141 *Fax:* 66-2-716-8218
*e-mail:* thairissho@csloxinfo.com

**Branches under the South Asia Division**

**Rissho Kosei-kai of Delhi**
77 Basement D.D.A. Site No. 1, New Rajinder Nagar,
New Delhi 110060, India

**Rissho Kosei-kai of Kolkata**
E-243 B. P. Township, P. O. Panchasayar, Kolkata 700094,
West Bengal, India

**Rissho Kosei-kai of Kolkata North**
AE/D/12 Arjunpur East, Teghoria, Kolkata 700059,
West Bengal, India

**Rissho Kosei-kai of Bodhgaya**
Ambedkar Nagar, West Police Line Road
Rumpur, Gaya-823001, Bihar, India

**Rissho Kosei-kai of Kathmandu**
Ward No. 3, Jhamsilhel, Sancepa-1, Lalitpur, Kathmandu,
Nepal

**Rissho Kosei-kai of Phnom Penh**
#201E2, St 128, Sangkat Mittapheap, Khan 7 Makara,
Phnom Penh, Cambodia

**Rissho Kosei-kai of Patna**
**Rissho Kosei-kai of Singapore**

**Thai Rissho Friendship Foundation**
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang
Bangkok 10310, Thailand
*Tel:* 66-2-716-8141 *Fax:* 66-2-716-8218
*e-mail:* info.thairissho@gmail.com

**Rissho Kosei-kai of Bangladesh**
85/A Chanmari Road, Lalkhan Bazar, Chittagong, Bangladesh
*Tel & Fax:* 880-31-626575

**Rissho Kosei-kai of Dhaka**
House#408/8, Road#7(West), D.O.H.S Baridhara,
Dhaka Cant.-1206, Bangladesh
*Tel & Fax:* 880-2-8413855

**Rissho Kosei-kai of Mayani**
Mayani(Barua Para), Post Office: Abutorab, Police Station:
Mirshari, District: Chittagong, Bangladesh

**Rissho Kosei-kai of Patiya**
Patiya, sadar, Patiya, Chittagong, Bangladesh

**Rissho Kosei-kai of Domdama**
Domdama, Mirsarai, Chittagong, Bangladesh

**Rissho Kosei-kai of Cox's Bazar**
Ume Burmese Market, Main Road Teck Para, Cox'sbazar,
Bangladesh

**Rissho Kosei-kai of Satbaria**
Satbaria, Hajirpara, Chandanish, Chittagong, Bangladesh

**Rissho Kosei-kai of Laksham**
Dupchar (West Para), Bhora Jatgat pur, Laksham, Comilla,
Bangladesh

**Rissho Kosei-kai of Raozan**
West Raozan, Ramjan Ali Hat, Raozan, Chittagong, Bangladesh

**Rissho Kosei-kai of Chendirpuni**
Chendirpuni, Adhunagor, Lohagara, Chittagong, Bangladesh

**Rissho Kosei-kai of Ramu**

**Rissho Kosei Dhamma Foundation, Sri Lanka**
No. 628-A, Station Road, Hunupitiya, Wattala, Sri Lanka
*Tel:* 94-11-2982406 *Fax:* 94-11-2982405

**Rissho Kosei-kai of Habarana**
151, Damulla Road, Habarana, Sri Lanka

**Rissho Kosei-kai of Polonnaruwa**

**Branches under the Headquarters**

**Rissho Kosei-kai di Roma**
Via Torino, 29-00184 Roma, Italia
*Tel & Fax:* 39-06-48913949 *e-mail:* roma@rk-euro.org

**Rissho Kosei-kai of the UK**
**Rissho Kosei-kai of Venezia**
**Rissho Kosei-kai of Paris**